# ប្រាសាទត្រពាំងខ្នារសែនកែវ

ប្រាសាទត្រពាំងខ្នារសែនកែវ[១] ស្ថិតនៅក្នុងភូមិស្រឡាយ ឃុំភ្នំត្បែងពីរ ស្រុកគូលែន ខេត្តព្រះវិហារ ដែលសព្វថ្ងៃព័ទ្ធជុំវិញដោយចម្ការដំឡូង និងចម្ការស្វាយចន្ទី។ ប្រាសាទនេះមានចម្ងាយ៤០០ម៉ែត្រពីភូមិស្រឡាយ និង៤៥គីឡូម៉ែត្រពីទីរួមខេត្តព្រះវិហារ។

កន្លងមក ប្រាសាទត្រពាំងខ្នារសែនកែវមានការសិក្សាស្រាវជ្រាវតាំងពីចុងសតវត្សទី១៩មកម្ល៉េះ ដែលអ្នកស្រាវជ្រាវដែលបានទៅដល់ដំបូងគេគឺលោក Aymonier[២] ក្រោយមកមានលោក Lunet De Lajonquière។[៣] នៅឆ្នាំ១៩២៩ លោក Henri Parmentier បានទៅសិក្សាពីប្រាសាទនេះរយៈពេល៥ថ្ងៃ ដោយបានសម្អាតចម្ងាក់ ព្រមទាំងលើកផ្តែរមួយចំនួនដាក់កន្លែងដើម និងបានកាយដីដែលចាក់បង្គរចេញពីប្រាង្គកណ្តាលជាដើម។ ក្រៅពីនេះមានអ្នកស្រាវជ្រាវមួយចំនួនទៀតដែលបានសិក្សាពីចម្លាក់និងរចនាសម្ព័ន្ធប្រាសាទនេះដែរ។ ក្នុងអត្ថបទនេះ យើងនឹងរៀបរាប់ពីលក្ខណៈសំណង់ស្ថាបត្យកម្មពីក្រៅចូលក្នុង ក្បាច់លម្អ និងចម្លាក់ផ្សេងៗក្នុងប្រាសាទ។

ប្រាសាទត្រពាំងខ្នារសែនកែវ មានរចនាសម្ព័ន្ធប្លង់គួរឱ្យចាប់អារម្មណ៍ និងលាតសន្ធឹងតាមអ័ក្សលិចកើត។ ប្រាសាទនេះចូលពីទិសខាងកើត ដោយចាប់ផ្តើមដោយកម្រាលថ្មភក់រាងកាកបាទមានប្រវែងជាង២៥០ម៉ែត្រពីគោបុរខាងកើត ដែលសម័យមុនប្រហែលជាសំណង់ឈើ និងប្រកក្បឿងពីលើ (រូបលេខ១)។ ផ្លូវចូលមានប្រវែង២៥០ម៉ែត្រ គិតចាប់ពីកម្រាលថ្មភក់មកដល់បរិវេណខាងមុខគោបុរខាងកើត (រូបលេខ២) ដែលមានបង្គោលថ្មនៅអមសងខាង និងឃ្លាតពីគ្នាជាមធ្យមមានប្រវែង២ម៉ែត្រកន្លះ ហើយសព្វថ្ងៃបង្គោលទាំងនោះបានដួលតម្រៀបគ្នានៅផ្លូវចូលស្ទើរតែទាំងអស់ (រូបលេខ៣)។ ប្រាសាទត្រពាំងខ្នារសែនកែវ ព័ទ្ធជុំវិញដោយកំពែងថ្មភក់រាងចតុកោណកែងបណ្តោយ៥៥ម៉ែត្រ និងទទឹង៤៥ម៉ែត្រ មានកម្ពស់ជាង២ម៉ែត្រកន្លះ កម្រាស់ជាមធ្យម៥០សង់ទីម៉ែត្រ (រូបលេខ៤) ដែលមានគោបុរពីរ គឺខាងកើត និងខាងលិច។ គោបុរខាងកើត មានច្រកចូលចំនួនបីសព្វថ្ងៃមានសភាពទ្រុឌទ្រោមយ៉ាងខ្លាំង (រូបលេខ៥)។ ចំណែកឯគោបុរខាងលិចមានច្រកចូលបីដូចគ្នាដែលមានសភាពទ្រុឌទ្រោមខ្លាំង (រូបលេខ៦)។ ដោយឡែកអ្វីដែលប្លែកនោះ ប្រាសាទនេះ

---

[១] ប្រាសាទនេះ តាមឯកសារអ្នកស្រាវជ្រាវពីមុនបង្ហាញថា អ្នកស្រុកខ្លះហៅប្រាសាទនេះថា ប្រាសាទត្រពាំងខ្នារសែនកែវ ខ្លះហៅប្រាសាទខ្នារសែនកែវ និងខ្លះទៀតហៅ ប្រាសាទខ្នារធំ។ ហើយសព្វថ្ងៃប្រជាជនហៅប្រាសាទនេះថា ប្រាសាទខ្នារ។

[២] Aymonier, 1900, 388

[៣] Lajonquière, 1902, 347-352

អត្ថបទដោយៈ ណែម ឆ៉ាន់

AMS
អរិយធម៌ខ្មែរ KHMER CIVILIZATION

មានគោបុរបញ្ចោទនៅខាងជើង និងខាងត្បូង ពោលគឺគេសង់បិទជិតមិនឱ្យចេញចូលបាន (រូបលេខ៧-៨)។ ផ្នែកខាងក្នុងកំពែង យើងឃើញថាផ្នែកខាងកើតមានហោត្រៃ២សង់ពីថ្មភក់ ហើយជាទូទៅសំណង់ប្រភេទនេះបែរបញ្រ្ចាសនឹងប្រាង្គកណ្តាល ដែលសព្វថ្ងៃរលំអស់ហើយ (រូបលេខ៩)។ ប្រាសាទត្រពាំងខ្នារសែនកែវ មានប្រាង្គកណ្តាលមួយ រាងបួនជ្រុងស្មើ សង់ពីថ្មភក់ បែរមុខទៅទិសខាងកើត ដែលលម្អដោយទ្វារបញ្ចោទតាមទិសទាំង៣ផ្សេងទៀត សព្វថ្ងៃនៅសល់តែខាងលិចប៉ុណ្ណោះ។ ប្រាង្គកណ្តាលសង់ភ្ជាប់មណ្ឌបដោយអន្តរមណ្ឌប និងបើកច្រកចេញចូលចំនួន៣នៅទិសខាងកើតខាងជើង និងខាងត្បូង (រូបលេខ១០)។

***ផ្តែរទ្វារ៖*** ប្រាសាទនេះមានផ្តែរទ្វារច្រើនរហូតដល់៣៩[៦] ប៉ុន្តែសព្វថ្ងៃឃើញតិចតួចប៉ុណ្ណោះ សុទ្ធសឹងតែស្ថិតក្នុងរចនាបថបាភួន មានកាលបរិច្ឆេទក្នុងសតវត្សទី១១ ដោយមានឆ្លាក់ជាតួអង្គអាទិទេព និងរឿងទេវកថាផ្សេងៗ។ ***ផ្តែរគោបុរខាងកើត៖*** ***ផ្តែរច្រកកណ្តាល***ស្ថិតនៅទីតាំងដើម ប៉ុន្តែមានការខូចខាតគួរសមដោយសារឫសឈើ និងរបេះសាច់ថ្ម ដែលនៅបន្សល់ក្បាច់ដងផ្ចូ និងក្បាលនាគនៅផ្នែកខាងឆ្វេងនៃផ្តែរ (រូបលេខ១១)។ ចំណែកឯ***ផ្តែរច្រកខាងជើង***មានសភាពល្អ លើកលែងតែចម្លាក់នៅចំកណ្តាលផ្តែរ ដែលត្រូវបានគេដាប់ចេញ។ យើងឃើញថានៅពីលើផ្តែរ មានលម្អដោយចម្លាក់មនុស្សអង្គុយប្រណម្យក្នុងអង្កែ (រូបលេខ១២)។ ដោយឡែក***ផ្តែរច្រកចូលខាងត្បូង*** បានជ្រុះ ហើយខ្ទាតមកមុខគោបុរ(រូបលេខ១៣)។ ***ផ្តែរទ្វារប្រាង្គកណ្តាល៖*** ***ផ្តែរទ្វារខាងលិច*** ស្ថិតនៅលើទ្វារបញ្ចោទ ចំកណ្តាលផ្តែរគេឆ្លាក់ព្រះនារាយណ៍ជិះគ្រុឌ ឬ***វិស្ណុវាហនៈ*** (រូបលេខ១៤)។ ផ្តែរនេះសព្វថ្ងៃមិនស្ថិតនៅទីតាំងដើមទេ ហើយក៏មិនប្រទះឃើញក្នុងបរិវេណប្រាសាទនោះដែរ ឬអាចកប់នៅក្រោមគំនរថ្មក៏ថាបាន។ ***ផ្តែរទ្វារខាងជើង*** ស្ថិតនៅលើទ្វារបញ្ចោទដែលចំកណ្តាលផ្តែរគេឆ្លាក់ឈុត ***ឧមាមហេស្វរ*** ដែលមានវត្តមានព្រះឥសូរ និងនាងឧមាគង់លើគោឈ្មោះនិន្ទិនជាយាន្តជំនិះនៅលើក្បាលព្រះកាល (រូបលេខ១៥)។ ខាងត្បូងប្រាង្គកណ្តាលមានផ្តែរមួយឆ្លាក់រឿង***ព្រះក្រឹស្ណាទ្រទ្រភ្នំគោវ៌ធន*** នៅចំកណ្តាលដែលប្រហែលជា***ផ្តែរខាងត្បូង*** ហើយបានជ្រុះខ្ទេចពីទីតាំងដើម (រូបលេខ១៦)។ ចំពោះ***ផ្តែរខាងកើត*** ស្ថិតនៅទីតាំងដើម ហើយនៅសេសសល់ក្បាច់លម្អច្រើន ប៉ុន្តែចម្លាក់កណ្តាលផ្តែរបានខូចខាតទៅហើយ ដែលសព្វថ្ងៃត្រូវបានថ្មផ្សេងទៀតធ្លាក់បាំងស្ទើរទាំងស្រុង (រូបលេខ១៧)។ ***ផ្តែរទ្វារមណ្ឌប៖*** ***ផ្តែរទ្វារខាងកើត*** សព្វថ្ងៃបានខ្ទាតមកត្បូងបន្តិចពីទីតាំងដើម ហើយបាក់ជា២កំណាត់ និងត្រូវបានគេដាប់ចម្លាក់នៅចំកណ្តាលចេញបាត់ហើយ (រូបលេខ១៨)។

[៦] Parmentier, 1939, 257

អត្ថបទដោយ៖ ណែម ធារ៉ាន់

**ផ្តែរទ្វារខាងជើង** ធ្លាក់ឈុត **ព្រះក្រឹស្នាសម្លាប់កាំស** នៅចំកណ្តាលក្នុងទម្រង់ចាប់ហែកខ្លួនកាំសជា២ (រូបលេខ១៩)។ ចំណែកឯ**ផ្តែរទ្វារខាងត្បូង** ធ្លាក់រឿង**កូរសមុទ្រទឹកដោះ** នៅពេញផ្ទៃផ្តែរតែម្តង ហើយផ្តែរនេះក៏មិនឃើញនៅទីតាំងដើមនោះដែរ (រូបលេខ២០)។ ចុងក្រោយ**ផ្តែរទ្វារខាងក្នុងមណ្ឌប** ធ្លាក់ឈុតរឿង **ព្រះក្រឹស្នាសម្លាប់ដំរីកុវលយ** នៅចំកណ្តាលផ្តែរ (រូបលេខ២១)។ យ៉ាងណាមិញអ្វីដែលគួរឱ្យសោកស្តាយនោះ នៅលើផ្តែរនេះ ពីមុនមានហោជាងមួយយ៉ាងស្រស់ស្អាត ហើយសព្វថ្ងៃបានរលំធ្លាក់អស់ហើយ (រូបលេខ២២)។ ហោជាងនេះលម្អដោយនាគក្បាល៣ចំនួន២អមសងខាង ដែលនៅចំកណ្តាលហោជាងធ្លាក់រូបទេពធំមួយ ទំនងជាព្រះនារាយណ៍លុតជង្គង់។ **សសរពេជ្រ** មានរាង៨ជ្រុង និងជាទូទៅលម្អដោយក្បាច់ចិញ្ចៀន។ **ចម្លាក់តូចៗ** ប្រាសាទនេះមានចម្លាក់ជាច្រើនដែលធ្លាក់នៅជញ្ជាំងផ្នែកខាងក្រៅ នៃមណ្ឌបស្រដៀងគ្នានឹងចម្លាក់នៅប្រាសាទបាភួនដែរ (រូបលេខ២៣-២៤) ហើយលក្ខណៈចម្លាក់ទាំងនេះ គេធ្លាក់ជាសាច់រឿងតូចៗដែលមានបន្ទាត់ខណ្ឌចែកសាច់រឿងពីគ្នា។ លោក Henri Parmentier បានសិក្សាលម្អិតអំពីចម្លាក់ទាំងនេះអំឡុងពេលនៅសេសសល់។[៩] ចម្លាក់ទាំងនេះគេធ្លាក់រឿងរ៉ាវរបស់ព្រះក្រឹស្នាដូចជា ក្រឹស្នាលួចប័រ ក្រឹស្នាទ្រភ្នំគោវ័ធន ក្រឹស្នាសម្លាប់បិសាច និងក្រឹស្នាសម្លាប់នាគកាលិយជាដើម។ ក្រៅពីនេះមានបង្ហាញពីការគោរពលិង្គព្រះឥសូរ និងចម្លាក់បង្ហាញពីការប្រយុទ្ធគ្នារវាងមនុស្សនិងមនុស្ស មនុស្សនិងសត្វ សត្វនិងសត្វ ព្រមទាំងជីវភាពរបស់នៅរបស់មនុស្ស និងបង្ហាញពីការបរបាញ់សត្វ។ល។ មកទល់បច្ចុប្បន្នឃើញមាននៅសល់ចម្លាក់នៅតែ៥កន្លែងប៉ុណ្ណោះដែលនៅទីតាំងដើម ហើយនៅសល់មិនពេញលេញនោះទេ (រូបលេខ២៥)។ នៅខាងជើងប្រាសាទ បន្សល់ត្រពាំងមួយ សព្វថ្ងៃប្រជាជនហៅថាត្រពាំងខ្នារ (រូបលេខ២៦)។

ជារួម ប្រាសាទត្រពាំងខ្នារសែនកែវជាសំណង់ធំមួយឧទ្ទិសទៅទេពក្នុងព្រហ្មញ្ញសាសនា ត្បិតយើងមិនអាចកំណត់ពីការឧទ្ទិសទៅទេពអង្គណាបានច្បាស់នោះឡើយ ដោយសារពុំមានភស្តុតាងជាសិលាចារឹក ឬរូបបដិមា ដើម្បីបញ្ជាក់ច្បាស់នោះទេ។ តាមរយៈគ្រឿងលម្អស្ថាបត្យកម្ម និងចម្លាក់ យើងអាចកំណត់ថាប្រាសាទនេះស្ថិតក្នុងរចនាបថបាភួន នៅសម័យអង្គរ នាសតវត្សទី១១ ក្នុងរាជព្រះបាទឧទ័យាទិត្យវរ្ម័នទី២ (គ.ស.១០៤៩-គ.ស.១០៦៦)។ សព្វថ្ងៃត្រពាំងខ្នារសែនកែវនេះមានសភាពទ្រុឌទ្រោមជាខ្លាំង ដោយសារកត្តាមនុស្ស និងធម្មជាតិ៕

[៩] សូមអានលម្អិតបន្ថែម Parmentier, 1939, 260-268

អត្ថបទដោយៈ ណែម ឆាវ៉ាន់

# ឯកសារពិគ្រោះ

AYMONIER, Etienne

1900, *Le Cambodge*, *Tome I*, Le royaume actuel, Éditeur ERNEST Leroux, École Française d'Extrême Orient, Paris.

BOISSELIER, Jean

1966, *Le Cambodge*, *Tome I*, Manuel d'archéologie d'Extrême-Orient, Éditions A. et J. Picard et Cie, Paris.

CORAL-RÉMUSAT, Gilberte

1951, L'Art Khmer, Les grandes Étapes de son Évolution, Étude d'art et d'ethnologie, Les Éditions d'art et d'histoire, Paris.

GLAIZE, Maurice

1941, Rapport de la Conservation d'Angkor, École Française d'Extrême-Orient.

LUNET DE LAJONQUIÈRE,Etienne Edmond

1902, *Inventaire Descriptif des Monuments du Cambodge, Volume IV, Tome I,* Éditeur ERNEST Leroux, École Française d'Extrême Orient, Paris.

Marchal, Henri

1928-1930, Journal de Fouille, No. VII, Conservation d'Angkor.

PARMENTIER, Henri

1939, *L'Art khmer Classique,* Monuments du quarant nord-est, L'École française d'Extrême-Orient, Paris.

## ABSTACT

Prasat Trapeang Khnar Sen Keo

Trapeang Khnar Sen Keo Temple

Prasat Trapeang Khnar Sen Keo is Angkorian period temple which constructed by sandstone and located in Preah Vihear Province. This temple was constructed in the 11th century in the Baphuon style during the reign of king Udayadityavarma II (1049-1066 C.E.), based on the architectural decoration and bas-relief remain. It is probably dedicated to a Hindu God but we don′t know exactly who is the main god is dedicated in this temple because it hasn′t remained any evident like the inscriptions or statues to verify. In the present time, we observed that this temple is in bad condition due to human and nature destruction.



រូបលេខ១៖ កម្រាលថ្មភក់



រូបលេខ២៖ ផ្លូវចូល



រូបលេខ៣៖ បង្គោលថ្ម



រូបលេខ៤៖ កំពែង



រូបលេខ៥៖ គោបុរខាងកើត



រូបលេខ៦៖ គោបុរខាងលិច

អត្ថបទដោយ៖ ណៃម ឆាវ៉ាន់



រូបលេខ៧៖ គោបុរបញ្ជោទខាងជើង



រូបលេខ៨៖ គោបុរបញ្ជោទខាងត្បូង



រូបលេខ៩៖ ហោត្រៃខាងត្បូង



រូបលេខ១០៖ ប្រាង្គកណ្ដាល និងមណ្ឌប



រូបលេខ១១៖ ផ្ដែរច្រកចូលកណ្ដាល គោបុរខាងកើត



រូបលេខ១២៖ ផ្ដែរច្រកខាងជើង គោបុរខាងកើត



រូបលេខ១៣៖ ផ្តែរច្រកចូលខាងត្បូង



រូបលេខ១៤៖ ផ្តែរទ្វារខាងលិចនៃប្រាង្គកណ្តាល
ប្រភពរូប៖ EFEO ( CAM11184 )



រូបលេខ១៥៖ ផ្តែរទ្វារខាងជើងនៃប្រាង្គកណ្តាល
ប្រភពរូប៖ EFEO ( CAM11225 )



រូបលេខ១៦៖ ផ្តែរទ្វារខាងត្បូងនៃប្រាង្គកណ្តាល



រូបលេខ១៧៖ ផ្តែរទ្វារខាងកើតនៃប្រាង្គកណ្តាល



រូបលេខ១៨៖ ផ្តែរទ្វារខាងកើតនៃមណ្ឌប



រូបលេខ២១៩៖ ផ្តែរទ្វារខាងជើងនៃមណ្ឌប

ប្រភពរូប៖ EFEO (CAM11226)



រូបលេខ២២០៖ ផ្តែរទ្វារខាងត្បូងនៃមណ្ឌប

ប្រភពរូប៖ EFEO (CAM11224)



រូបលេខ២២១៖ ផ្តែរទ្វារខាងក្នុងមណ្ឌប



រូបលេខ២២២៖ ហោជាងខាងក្នុងមណ្ឌប

ប្រភពរូប៖ EFEO (CAM11183)



រូបលេខ២២៣៖ ចម្លាក់តូចៗធ្លាក់នៅមណ្ឌប

ប្រភពរូប៖ EFEO (CAM11180)



រូបលេខ២២៤៖ ចម្លាក់តូចៗធ្លាក់នៅមណ្ឌប

ប្រភពរូប៖ EFEO (CAM11179)

អត្ថបទដោយ៖ ណែម ឆាវ៉ាន់



រូបលេខ២៥៖ ចម្លាក់តូចៗឆ្លាក់នៅមណ្ឌប ដែលនៅសេសសល់ពេលបច្ចុប្បន្ន



រូបលេខ២៦៖ ត្រពាំង